**សាររបស់លោកអគ្គនាយកការិយាល័យអន្តរជាតិ**
**នៃសហភាពប្រៃសណីយ៍សកលក្នុងឱកាសទិវាប្រៃសណីយ៍ពិភពលោក ០៩ តុលា**

**ទិវាប្រៃសណីយ៍ពិភពលោក ២០០៩**
**សារពីលោកអគ្គនាយក**
**សេវាប្រៃសណីយ៍ធ្វើឲ្យមានការរីកលូតលាស់បៃតង**

ការការពារបរិស្ថាន និងអាកាសធាតុប្រែប្រួល ធ្វើឲ្យមានការប្រឈមមុខខ្លាំង ដែលទោះបីជាមានការយកចិត្តទុកដាក់គិតគូរលើបញ្ហានេះក៏ដោយ តែផែនដី និងប្រជាជននៅតែមិនប្រសើរគ្រប់គ្រាន់ក្នុងការទទួលខ្យល់អាកាសបរិសុទ្ធសំរាប់ដកដង្ហើម។ បច្ចុប្បន្ននេះវាក្លាយទៅជាបញ្ហាដ៏សំខាន់សំរាប់យើងទាំងអស់គ្នា ដើម្បីធ្វើការរៀបចំ និងផ្លាស់ប្តូររបៀបនៃការប្រើប្រាស់ថាមពលនេះ។

វិស័យប្រៃសណីយ៍ពិភពលោកមិនអាចព្រងើយកន្តើយដោយមិនធ្វើអ្វីសោះនោះទេ ៖ ការចែកជូនលិខិត ៤៣០កោដ្ឋ( 430 Billion) និងប្រៃសណីយ៍ភ័ណ្ឌចំនួន ៦កោដ្ឋ(6 Billion) ទូទាំងពិភពលោកក្នុងមួយឆ្នាំៗទាំងនោះប្រតិបត្តិដោយជាង ៦០០០០០ គ្រឹះស្ថាន និងយានយន្តជាច្រើន ដែរលនឹងត្រូវធ្វើឲ្យទៅជាអ្នកផលិតឧស្ម័នកខ្វក់ (Greenhouse gas) ដ៏សំខាន់។ ក៏ដូចជាស្ថាប័នដទៃទៀតដែរ
យើងត្រូវតែពិនិត្យឲ្យបានច្បាស់លាស់នូវមធ្យោបាយផ្សេងៗដើម្បីប្រែក្លាយអាកាសធាតុឲ្យទៅជាធម្មតាវិញ។

ក្រោមការជួយឧបត្ថម្ភគាំទ្រគំរោងអភិវឌ្ឍន៍ប្រកបដោយចិរភាព (Sustainable Development Project Group) របស់សហភាពប្រៃសណីយ៍សកល ដេលជាភ្នាក់ងារទទួលខុសត្រូវលើជំនាញប្រៃសណីយ៍បានធ្វើកិច្ចការស្រាវជ្រាវនេះនៅឯសន្និសិទ្ធអង្គាសហប្រជាជាតិស្តីពីបំលាស់ប្តូអាការសធាតុដែលនឹងធ្វើនៅទីក្រុង Copenhagen (Denmark) នាខែធ្នូខាងមុខ។ ពេលនោះដោយមានជំនួយពីកម្មវិធីបរិស្ថានសហប្រជាជាតិ ដែលយើងបានចុះហត្ថលេខាជាមួយគ្នាពីឆ្នាំមុនរួមជាមួយដៃគូរដ៏ទៃ យើងនឹងស្នើរវិធានការណ៍មួយចំនួនសមស្រប ដើម្បីប្រតិបត្តិករប្រៃសណីយ៍ធ្វើការកាត់បន្ថយការភាយចេញឧស្ម័នកាបូនិច ($CO_2$)។

ប្រសណីយ៍ទាំងឡាយជាភ្នាក់ងារដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរ។ ក្នុងឱកាសទិវាប្រៃសណីយ៍សកល ២០០៩ នេះ ខ្ញុំសូមអំពាវនាវចំពោះគ្រប់សមាជិកទាំងអស់នៃក្រុមគ្រួសារប្រៃសណីយ៍ ចូរគិតគូរដោយយកចិត្តទុកដាក់អំពីផលប៉ះពាល់បរិស្ថាននៃសមកម្មភាពរបស់យើងទាំងអស់គ្នា(ប្រសិនបើយើងមិនទាន់បានធ្វើអ្វីឲ្យប៉ះពាល់ ដើម្បីចូលរួមពិភាក្សាក៏មានអត្ថន័យអំពីមធ្យោបាយដ៏ប្រសើរក្នុងការការពារផែនដី។

ក្នុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការគ្រប់គ្រងបញ្ហាបរិស្ថានអាចជាកំលាំងជំរុញដ៏សំខាន់ក្នុងការជួយឲ្យមានការរីកលូតលាស់។ ដើម្បីឲ្យដល់ការរីកលូតលាស់បៃតងអាជីវិកម្មត្រូវគិតគូរដល់ដំណើរការសង្វាក់ភស្តុភា លើកកំពស់ប្រសិទ្ធភាពលើវិធានការណ៍សន្សំថាមពលរយៈពេលវែង អភិវឌ្ឍន៍ផលិតផល និងសេវាកម្មដែលថ្មីដែលធ្វើឲ្យមានការប៉ះពាល់តិចតួចដល់បរិស្ថាន និងមានការទាក់ទាញដល់អតិថិជន ហើយជាចុងក្រោយបង្ហាញនូវភាពទទួលត្រូវ។

សកម្មភាពរបស់លោកអ្នក ក្នុងក្របខ័ណ្ឌសហភាពប្រៃសណីយ៍សកល ក្នុងអាជីវកម្មរបស់លោកអ្នក ឬក្របខ័ណ្ឌរដ្ឋបាលរបស់លោកអ្នក គឺមានសារៈប្រយោជន៍ណាស់។ យើងជំរុញលោកអ្នក សូមឲ្យទៅមុខបន្ថែមទៀត ដោយអនុវត្តឲ្យបានម៉ឺងម៉ាត់ទៅតាមនទិសស្លោករបស់សហប្រជាជាតិ "**ចូរកៀកស្នាគ្នា**" "Let's Seal the Deal" ។ គមនិតផ្តួចផ្តើមនេះមានគោលបំណងធ្វើឲ្យមានចលនាគាំទ្រឲ្យមានបុគ្គលរាប់លាននាក់ អង្គភាពអាជិវកម្មផ្សេងៗ ក្រុមសហគមន៍ និង អង្គការដ៏ទៃទៀត ចូលរួមចុះហត្ថលេខានៅឯសន្និសិទ្ធស្តីអំពីបំលាស់ប្តូរអាកាសធាតុនាទីក្រុង Copenhagen ជាសទ្ធិសញ្ញាអន្តរជាតិថ្មីមួយក្នុងការកាត់បន្ថយការភាយចេញឧស្ម័នកខ្វក់ (Greenhouse gas) ។ សហភាពប្រៃសណីយ៍សកល នឹងមិនបរាជ័យដើម្បីបញ្ចេញសំលេង នៃវិស័យប្រៃសណីយ៍ឲ្យឮនៅឯសន្និសិទ្ធនេះ ធ្វើឲ្យឮសំលេងលោកអ្នកដែរ ដោយអស់លោកអ្នកអាចធ្វើជាញ្ញតិលើគេហទំព័រ [www.sealthedeal2009.org/petition](www.sealthedeal2009.org/petition) និងសូមយកឱកាសទាំងអស់ជំរុញបុគ្គលិករបស់លោកអ្នក និងអតិថិជនលោកអ្នកក្នុងការចូលរួមផង។

ខ្ញុំសូមជូនពរឲ្យទិវាពិភពលោកនៃប្រៃសណីយ៍ឆ្នាំ ២០០៩ នេះប្រព្រឹត្តទៅដោយជោគជ័យបំផុត។